00901229

002/19-09-2007-ECCC/TC
E1/175

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 04 / 2013
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ច័ន្ទ ទី ២៥ ខែ មីនា ឆ្នាំ ២០១៣

## សវនាការលើការវាយតម្លៃសុខភាពជនជាប់ចោទ នួន ជា

រៀបចំដោយ: ដាវ អានសាន និង Matteo CRIPPA

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, លោក Matteo CRIPPA |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក Andrew CAYLEY, លោក Dale LYSAK |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ) |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, |

| |
|---|
| លោក ឡៅ ជុនធី, លោកស្រី Christine MARTINEAU, លោកស្រី ស៊ិន សូវន, លោក សំ សុគង់, លោក ហុង គីមសួន, លោក វ៉ែន ពៅ, លោកស្រី ជេត វ៉ាន់លី |
| អ្នកជំនាញ៖ សាស្ត្រាចារ្យ John CAMPBELL និងវេជ្ជបណ្ឌិត Seena FAZEL |
| សាក្សី/ដើមបណ្ដឹងរដ្ឋប្បវេណី៖ មិនមាន |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោកស្រី សួ សុទ្ធារី, លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក Simon MEISENBERG, លោក Grant RAGLAND |

**<u>ពេលវេលាទូទៅរបស់តុលាការ៖</u>**

| | | |
|---|---|---|
| ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ | ចាប់ផ្ដើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.00 |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៣៥ | បញ្ចប់ម៉ោង៖ ១១.00 |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១២.១០ | បញ្ចប់ម៉ោង៖ ១៣.៤០ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.២៥ | បញ្ចប់ម៉ោង៖ ១៤.៤៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ៤០ នាទី | | |

**<u>កិច្ចដំណើរការនីតិវិធី៖</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| អង្គជំនុំជម្រះប្រកាសបើកសវនាការ និងរំលឹកនីតិវិធីពាក់ព័ន្ធ | អង្គជំនុំជម្រះ | ០៩.០៤ | ០៩.២០ |
| ការផ្ដល់សក្ខីកម្មរបស់អ្នកជំនាញវេជ្ជសាស្ត្រអំពីសុខភាពជនជាប់ចោទ នួន ជា | អង្គជំនុំជម្រះ<br>មេធាវីការពារក្ដី នួន ជា<br>សហព្រះរាជអាជ្ញា<br>មេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី | ០៩.២២<br>១១.00<br>១១.៣០<br>១៣.៤០ | ១១.00<br>១១.៣០<br>១២.១០<br>១៣.៥៨ |
| ការលះបង់សិទ្ធិរបស់ ខៀវ សំផន ក្នុងការចូលរួមសវនាការ | អង្គជំនុំជម្រះសាលាដំបូង | ១៣.៣៧ | ១៣.៣៩ |
| សេចក្ដីសន្និដ្ឋានបញ្ចប់របស់ភាគីលើបញ្ហាសុខភាពរបស់ជនជាប់ចោទ នួន ជា | មេធាវីការពារក្ដី នួន ជា<br>សហព្រះរាជអាជ្ញា<br>មេធាវីនាំមុខដើមបណ្ដឹង | ១៤.00<br>១៤.០៥ | ១៤.០៥<br>១៤.១១ |

| | | | |
|---|---|---|---|
| | រដ្ឋប្បវេណី | ១៤.១១ | ១៤.២០ |
| | មេធាវីការពារក្តី នួន ជា តប | ១៤.២០ | ១៤.២៤ |
| កិច្ចពិភាក្សាអំពីផលប៉ះពាល់ដែលអាចកើតចេញពីសេចក្តីសម្រេច ដែលអាចបំបែក ឬមិនបំបែកជនជាប់ចោទ នួន ជា | មេធាវីការពារក្តី នួន ជា | ១៤.៤៧ | ១៤.៤៩ |
| | មេធាវី ខៀវ សំផន | ១៤.៤៩ | ១៤.៥១ |
| | សហព្រះរាជអាជ្ញា | ១៤.៥១ | ១៤.៥៣ |
| | អង្គជំនុំជម្រះ | ១៤.៥៣ | ១៤.៥៥ |
| | សហព្រះរាជអាជ្ញា | ១៤.៥៥ | ១៥.០១ |
| | មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី | ១៥.០២ | ១៥.១១ |
| | អង្គជំនុំជម្រះ | ១៥.១១ | ១៥.៤៦ |
| ការប្រកាសរបស់អង្គជំនុំជម្រះអំពីការចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងសុខភាព នួន ជា | អង្គជំនុំជម្រះ | ១៥.៤៩ | ១៥.៥០ |
| នីតិវិធីសម្បថចូលបម្រើការងាររបស់អ្នកស៊ើបអង្កេតនៃការិយាល័យហាចៅក្រមស៊ើបអង្កេត | អង្គជំនុំជម្រះ | ១៥.៥០ | ១៥.៥៨ |

<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>

**អង្គជំនុំជម្រះប្រកាសបើកសវនាការ និងរំលឹកនីតិវិធីពាក់ព័ន្ធ**

ប្រធានអង្គជំនុំជម្រះប្រកាសបើកសវនាការ ដែលនឹងដំណើរការជាពីរដំណាក់កាល៖ ទីមួយ ស្តាប់សក្ខីកម្មរបស់អ្នកជំនាញវេជ្ជសាស្ត្រ និងទីពីរ ភាគីពាក់ព័ន្ធពិភាក្សាដេញដោលលើបញ្ហាសុខភាពរបស់ជនជាប់ចោទ នួន ជា។ ប្រធានអង្គជំនុំជម្រះបន្តរំលឹកនីតិវិធីពាក់ព័ន្ធ និងការប្រកាសហេតុ ទាក់ទងនឹងការបើកសវនាការនេះ។ មេធាវីជនជាប់ចោទ យល់ព្រមថា សវនាការនេះអាចធ្វើជាសាធារណៈ ជាគោលការណ៍។

**ការផ្តល់សក្ខីកម្មរបស់អ្នកជំនាញវេជ្ជសាស្ត្រនៅលើសុខភាពជនជាប់ចោទ នួន ជា**

ប្រធានអង្គជំនុំជម្រះចាប់ផ្តើមសំណួរបឋម ចំពោះអ្នកជំនាញ John A. Campbell និងជាបន្តបន្ទាប់ចំពោះវេជ្ជបណ្ឌិត Seena Fazel អំពីព័ត៌មានប្រវត្តិរូបទូទៅ។ អ្នកជំនាញទាំងពីរ ធ្វើសម្បថនៅចំពោះមុខសវនាការ។ អង្គជំនុំជម្រះចាប់ផ្តើមសួរសំណួរដល់អ្នកជំនាញទាំងពីរ ពាក់ព័ន្ធនឹងរបាយការណ៍វេជ្ជសាស្ត្រចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ស្តីពីការវាយតម្លៃសម្បទាជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ

(ឯកសារ E256)។ ជាបន្តបន្ទាប់ មេធាវីការពារក្តី នួន ជា, សហព្រះរាជអាជ្ញា, មេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី សួរសំណួរចំពោះអ្នកជំនាញទាំងពីរ។ អង្គជំនុំជម្រះសាលាដំបូងផ្តល់ឱកាសឲ្យមេធាវីការពារក្តី ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់លើបញ្ហាសុខភាពរបស់ នួន ជា។

**ការលះបង់សិទ្ធិរបស់ ខៀវ សំផន ក្នុងការចូលរួមសវនាការ**

ជនជាប់ចោទ ខៀវ សំផន លះបង់សិទ្ធិក្នុងការចូលរួមសវនាការដែលពាក់ព័ន្ធនឹងគាត់ នាវេលារសៀលដែលពិភាក្សាអំពីការបំបែកកិច្ចដំណើរការនីតិវិធី។

**សេចក្តីសន្និដ្ឋានបញ្ចប់របស់ភាគីលើបញ្ហាសុខភាពរបស់ជនជាប់ចោទ នួន ជា**

ជាបន្តបន្ទាប់ មេធាវីការពារក្តី, សហព្រះរាជអាជ្ញា, និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានបញ្ចប់លើរបាយការណ៍ និងសក្ខីកម្មរបស់អ្នកជំនាញ។ មេធាវីការពារក្តី ត្រូវបានផ្តល់ឱកាសធ្វើសេចក្តីសន្និដ្ឋានតបបញ្ចប់ចុងក្រោយ។

**កិច្ចពិភាក្សាអំពីផលប៉ះពាល់ដែលអាចកើតចេញពីសេចក្តីសម្រេច ដែលអាចបំបែក ឬមិនបំបែក ជនជាប់ចោទ នួន ជា**

អង្គជំនុំជម្រះផ្តល់ឱកាសដល់ភាគី ធ្វើការពិភាក្សាអំពីស្ថានភាពសុខភាពរបស់ នួន ជា និងផលប៉ះពាល់នានាដែលអាចកើតមានឡើង ក្នុងករណីមានការបំបែកកិច្ចដំណើរការនីតិវិធី សំណុំរឿង ០០២/០១។

**ការប្រកាសរបស់អង្គជំនុំជម្រះអំពីការចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងសុខភាព នួន ជា**

អង្គជំនុំជម្រះប្រកាសថា នឹងចេញសេចក្តីសម្រេចទាក់ទងនឹងសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ នៅក្នុងសវនាការថ្ងៃ សុក្រ ទី ២៩ ខែ មីនា ឆ្នាំ ២០១៣។

**នីតិវិធីសម្បថចូលបម្រើការងាររបស់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត**

លោកស្រី PLANTE Julie ធ្វើសម្បថចូលបម្រើការងារជាអ្នក ស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។

<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ យោងតាមអនុសាសន៍របស់វេជ្ជបណ្ឌិតប្រចាំការនៅ អវតក និងបង្គាប់ឲ្យ

មានការភ្ជាប់ប្រព័ន្ធសោតទស្សន៍ដើម្បីផ្តល់លទ្ធភាពឲ្យជនជាប់ចោទតាមដានសវនាការពីចម្ងាយ។

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ ខៀវ សំផន លះបង់សិទ្ធិមិនចូលរួមសវនាការ សម្រាប់សវនាការវេលារសៀល ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ និងបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ខៀវ សំផន ទៅមន្ទីរឃុំឃាំង។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ។

<u>**កាលបរិច្ឆេទបន្តសវនាការ៖**</u>

សវនាការនឹងបន្តនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៣ វេលាម៉ោង ៩ ព្រឹក។

ភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ដាវ អានសាន** **Matteo CRIPPA**